Department of Education and Early Childhood Development

Literacy tips to help your child
Years 3–6
Khmer

# គន្លឹះអក្ខរកម្មខ្លះៗ ដើម្បីជួយកូនរបស់អ្នក

ថ្នាក់ទី៣ - ៦

## កុមារ រាល់រូប ឱកាស គ្រប់យ៉ាង










ក្រុមគ្រួសារគឺជាអ្នកមានឥទ្ធិពលមុនគេ និងជាប់លាប់ជាងគេចំពោះការលូតលាស់របស់កុមារ ហើយគ្រួសារក៏ដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការសិក្សារៀនសូត្ររបស់កុមារដែរ។

មានវិធីច្រើនយ៉ាងដែលអ្នកអាចបង្កើត និងគាំទ្រដល់ការវិវឌ្ឍជំនាញនៃការនិយាយ, ការស្តាប់, ការសរសេរ និងការអាននៃកូនរបស់អ្នកតាមរយៈការលេង និងសកម្មភាពប្រចាំថ្ងៃជាច្រើនរបស់គ្រួសារ។

ប័ណ្ណព័ត៌មាននេះផ្តល់ជាគំនិតខ្លះៗដែលអ្នក ឬសមាជិកគ្រួសារដទៃទៀតរបស់អ្នកអាចធ្វើជាមួយនឹងកូនរបស់អ្នកនៅក្នុងសកម្មភាពប្រចាំថ្ងៃនានាដើម្បីពង្រឹង និងពង្រីកចំណេះអក្ខរកម្មរបស់ពួកគេ។

ប្រសិនបើអ្នកមានទំនុកចិត្តខ្លួនឯងនោះ ការឲ្យកូនរបស់អ្នកចូលរួមនៅក្នុងសកម្មភាពទាំងនេះ ជាភាសាទីមួយរបស់ពួកគេ និងជាភាសាអង់គ្លេសគឺអាចហុចនូវប្រយោជន៍យ៉ាងល្អ។

ប័ណ្ណព័ត៌មាននេះក្នុងទម្រង់អេឡិចត្រូនិកក៏មានជូនជាភាសាអង់គ្លេស និង២៣ភាសាដទៃទៀតដែរពីវិបសាយថ៍គ្រួសារជាដៃគូនៅក្នុងការសិក្សា៖ **www.education.vic.gov.au/about/directions/familiesaspartners/schools/connecting.htm**

## តើខ្ញុំអាចទទួលជំនួយពីណា?

### គ្រូរបស់កូនអ្នក

គ្រូរបស់កូនអ្នកអាចផ្តល់ឱវាទអំពីវិធីដែលអ្នកអាចជួយពង្រឹង និងពង្រីកចំណេះដឹងខាងអក្ខរកម្មនៃកូនរបស់អ្នក។ ប្រធានបទខ្លះៗដែលអ្នកអាចពិភាក្សាជាមួយនឹងលោកគ្រូអ្នកគ្រូរួមមាន៖

- កម្រិតជោគជ័យលើកិច្ចការអក្ខរកម្មនៃកូនរបស់អ្នក។
- គោលដៅអក្ខរកម្មផ្សេងៗដែលកូនរបស់អ្នកកំពុងតែខិតខំរៀនដើម្បីសម្រេចឲ្យបាន និងរបៀបដែលអ្នកអាចជួយគាំទ្រកូនរបស់អ្នកនៅក្នុងការសម្រេចទិសដៅទាំងនេះ។
- វិធីសាស្ត្រផ្សេងៗដែលអ្នកអាចប្រើដើម្បីជួយកូនរបស់អ្នកនៅក្នុងផ្នែកដែលកូនរបស់អ្នកមានការលំបាក។

### ធនធានឯកសារ និងសម្ភារនៅលើបណ្តាញអ៊ីនធើណេត

វិបសាយថ៍ *Connect-Primary* ថ្មីរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀបង្កលក្ខណៈងាយស្រួលនៅក្នុងការភ្ជាប់ទៅឧបករណ៍សិក្សាល្អៗពីកុំព្យូទ័ររបស់អ្នកនៅផ្ទះ, ពីកុំព្យូទ័រនៅបណ្ណាល័យក្នុងតំបន់ ឬក៏អាចភ្ជាប់ពីកុំព្យូទ័រនៅសាលារៀនរបស់អ្នក។

បើកមើលវិបសាយថ៍ *Connect-Primary* នៅអាសយដ្ឋាន **http://www.education.vic.gov.au/primary**

វិបសាយថ៍ផ្សេងៗដែលមាននៅក្នុងវិបសាយថ៍ *Connect-Primary* ត្រូវបានលោកគ្រូអ្នកគ្រូឆែកមើល ដើម្បីធានាឲ្យបានថាវិបសាយថ៍ទាំងនោះសមរម្យសម្រាប់កុមារ។

ត្រូវចងចាំថា ប្រសិនបើអ្នកចូលមើលវិបសាយថ៍ដទៃទៀតដែលមិនមានរាយឈ្មោះនៅក្នុងបញ្ជីលើវិបសាយថ៍ *Connect-Primary* ទេនោះ ដើម្បីសុវត្ថិភាពអ្នកមិនគួរផ្តល់ព័ត៌មានលម្អិត ដូចជាឈ្មោះរបស់អ្នក ឬឈ្មោះពេញនៃកូនរបស់អ្នក, សាលារៀន, លេខទូរស័ព្ទ ឬក៏អាសយដ្ឋាន ទៅឲ្យជូនណាម្នាក់ដែលអ្នកមិនស្គាល់នៅលើបណ្តាញអ៊ីនធើណេតឡើយ។

*Ultranet* គឺជាប្រព័ន្ធថ្មីមួយតាមអ៊ីនធើណេតដែលផ្តល់ជូនអ្នកនូវព័ត៌មានអំពីការសិក្សារៀនសូត្រនៃកូនរបស់អ្នកនៅឯសាលារៀន។ ប្រព័ន្ធថ្មីនេះគឺជាប្រព័ន្ធប្រើទូទាំងរដ្ឋដែលមានសុវត្ថិភាពដែលសិស្ស, មាតាបិតា និង លោកគ្រូអ្នកគ្រូអាចបើកមើលបានតាមអ៊ីនធើណេត។ បើកមើលវិបសាយថ៍ *Ultranet* នេះនៅ៖ **www.education.vic.gov.au/about/directions/ultranet/benefits/parents.htm**

# ការជួយកូនរបស់អ្នកឲ្យចេះ អាន សរសេរ មើល

## បង្កើតឲ្យមានឱកាសផ្សេងៗសម្រាប់ការអាន និងការសរសេរនៅផ្ទះ៖

ក្នុងនាមជាអ្នកអាន និងអ្នកសរសេរ កុមារតូចៗធ្វើការរុករកនៅក្នុងពិភពរបស់គេរាល់ថ្ងៃ មិនត្រឹមតែនៅសាលា និងនៅផ្ទះនោះទេ។



ជាការសំខាន់ដែលអ្នកត្រូវ៖

- បង្ហាញឲ្យឃើញនូវចំណាប់អារម្មណ៍ពិតប្រាកដចំពោះការអាន និងការសរសេររបស់កូនអ្នក ហើយត្រូវពិនិត្យមើលចំពោះការសរសេរគ្រប់ប្រភេទទាំងអស់។
- ឲ្យឱកាសពួកគេមើលអ្នកអាន និងសរសេរ ហើយប្រាប់ពួកគេនូវមូលហេតុដែលអ្នកកំពុងអាន និងសរសេរ។
- និយាយជាមួយកូនរបស់អ្នកអំពីការយល់ឃើញរបស់ពួកគេ និងជំរុញលើកទឹកចិត្តកិច្ចប្រឹងប្រែងអាន និងសរសេររបស់ពួកគេ។
- ចែករំលែក និងនិយាយប្រាប់អំពីប្រវត្តិគ្រួសារ និងរឿងផ្សេងៗតាមរយៈការនិយាយពិភាក្សា និងជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកនិយាយជាមួយនឹងសមាជិកដទៃទៀតក្នុងក្រុមគ្រួសារដែលមានវ័យចាស់ជាង។
- ពិភាក្សាអំពីកម្មវិធីទូរទស្សន៍ ឬក៏ភាពយន្តផ្សេងៗ ដែលអ្នកបានមើលជាមួយគ្នា។
- ជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកបង្កើតឲ្យមាននូវបណ្ណាល័យសៀវភៅរបស់គេផ្ទាល់។
- និយាយពិភាក្សាអំពីព្រឹត្តិការណ៍ពិភពលោកនានា ហើយជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកពិនិត្យមើល ដំណើររឿងឲ្យបានគ្រប់ជ្រុងជ្រោយខុសៗគ្នា ដើម្បីផ្តើមគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។

## ការគាំទ្រកូនរបស់អ្នកក្នុងការអាន និងការសរសេរនៅផ្ទះ៖

បង្កើតឲ្យមាននូវទម្លាប់រៀនសូត្រ ហើយផ្តល់សម្ភារផ្សេងៗដើម្បីជាការលើកទឹកចិត្តឲ្យកូនចង់សរសេរ៖



- កូនសៀវភៅកត់ត្រាសម្រាប់សរសេរទុកនូវគំនិតនិងអារម្មណ៍ផ្សេងៗរបស់គេ។
- កុំព្យូទ័រ និង/ឬ កុំព្យូទ័រយួរដៃ។
- ខ្មៅដៃ, ប៊ិកសម្រាប់គូសចំណាំ, ហ្វឺត សម្រាប់គូសសម្គាល់ និងប៊ិក។
- វចនានុក្រមពាក្យ និងវចនានុក្រមសទិសន័យសម្រាប់ជាឯកសារយោង។ ឯកសារទាំងនេះអាចជាសៀវភៅ ឬក៏ប្រើលើបណ្តាញអ៊ីនធើណេត។
- សម្ភារ ឬឯកសារផ្សេងៗដែលមានលើវិបសាយថ៍ដូចជា ផែនទីលើអ៊ីនធើណេត, អេនសៃក្លូភីឌៀ, វិបសាយថ៍មើលអាកាសធាតុជាដើម។

### ចែករំលែកគំនិតផ្សេងៗអំពីអត្ថបទនានា



ក្រោយពីកូនរបស់អ្នកបានអានអត្ថបទណាមួយហើយ ជំរុញលើកទឹកចិត្តឲ្យកូននិយាយអំពីអត្ថបទនោះ។

ខាងក្រោមនេះគឺជាគំនិតមួយចំនួនដែលអាចសមស្របទៅនឹងចំណាប់អារម្មណ៍កូនរបស់អ្នក៖

- អានអំពីអ្នកនិពន្ធ ឬអ្នកគូររូបភាពនៅលើវ៉ិបសាយថ៍របស់ពួកគេ។
- ស្វែងរក និងអានរឿងមួយទៀតដែលបានតែងឡើងដោយអ្នកនិពន្ធតែមួយ។
- ធ្វើទៅតាមសេចក្ដីណែនាំផ្សេងទាំងឡាយនៅក្នុងអត្ថបទដើម្បីបង្កើតនូវអ្វីមួយ ឧទាហរណ៍ដូចជាក្បួនធ្វើម្ហូប, ការធ្វើម៉ូដែល, ការបត់ក្រដាសជាដើម។ សាកល្បង ការបត់ក្រដាសធ្វើជាវត្ថុអ្វីមួយ (តាមក្បួនរបស់ជប៉ុន)។ សូមចូលមើលវ៉ិបសាយថ៍ខាងក្រោមនេះដើម្បីមើលគំរូ និងសេចក្ដីណែនាំផ្សេងៗ **http://www.origami.com/index.html**
- គូររូប និងផាត់ពណ៌គំនូរផ្សេងៗអំពីទេសភាព ឬក៏តួអង្គនានានៅក្នុងរឿងណាមួយ។ គូររូបទាំងនេះលើអ៊ីនធើរណិតតាមរយៈការចុចនៅលើពាក្យ *Draw* ដែលមានភ្ជាប់នៅលើវ៉ិបសាយថ៍កម្មវិធី *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។
- អានអត្ថបទផ្សេងៗជាមួយគ្នាអំពីបញ្ហាតែមួយ ដើម្បីឲ្យដឹងនូវមតិយោបល់លើសពីមួយ។ ធ្វើការពិភាក្សាអំពីទស្សនៈខុសៗគ្នាដែលបានបញ្ចេញនៅក្នុងអត្ថបទទាំងនោះ។
- ទស្សនាខ្សែភាពយន្តដែលយកលំនាំតាមសៀវភៅ ហើយធ្វើការប្រៀបធៀប។
- ជ្រើសរើសរូបភាពមួយចំនួនសម្រាប់តួអង្គ ឬឆាកណាមួយតាមរយៈការចុចនៅកន្លែង Images ដែលមានភ្ជាប់នៅលើវ៉ិបសាយថ៍កម្មវិធី *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។

## ការសួរកូនរបស់អ្នកនូវសំណួរផ្សេងៗ

តាមរយៈការសួរសំណួរជាច្រើន អ្នកអាចជួយកូនរបស់អ្នកឲ្យចេះ៖

- ចែករំលែកសេចក្ដីរំភើបរីករាយរបស់គេអំពីការអាន និងការសរសេរ។
- បណ្ដុះបណ្ដាលការយល់ដឹងឲ្យកាន់តែច្បាស់ជាងមុនអំពីតួអង្គផ្សេងៗ ឬក៏ប្រធានបទនានា។
- បង្កើតឲ្យមានទឹកចិត្តយល់ដល់អារម្មណ៍របស់អ្នកដទៃ។
- បង្កើតនូវតម្លៃ អត្តចរិត និងជំនឿផ្សេងៗ របស់ពួកគេអំពីពិភពលោក។
- ពង្រីកបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេឲ្យបានទូលំទូលាយអំពីពិភពលោក។
- បណ្ដុះបណ្ដាលនូវការស្រមើស្រមៃរបស់ពួកគេ។
- គិតគូរពិចារណាអំពីចំណុចសំខាន់ៗដែលមាននៅក្នុងអ្វីដែលពួកគេកំពុងអាន។

ខាងក្រោមនេះគឺជាប្រភេទសំណួរជាច្រើនដែលកូនរបស់អ្នកអាចសួរនាំនៅឯសាលារៀន។ អ្នកក៏អាចបញ្ចូលសំណួរទាំងនេះខ្លះបានដែរ នៅពេលដែលអ្នកពិភាក្សាអំពីការអាននៅផ្ទះ។

- តើតួអង្គទាំងនោះមានឈ្មោះអ្វីខ្លះ?
- តើអ្វីទៅជាឆាកឈុតនៅក្នុងសាច់រឿងនោះ?
- តើតួអង្គបានធ្វើអ្វីទៀតបន្ទាប់ពីនោះ?
- តើអ្វីបានកើតឡើងនៅពេលចាប់ផ្ដើម/ទីបញ្ចប់នៃសាច់រឿង?
- តើកូនគិតថាតួអង្គមានអារម្មណ៍យ៉ាងណា?
- តើកូនអាចចង់ផ្លាស់ប្ដូរក្ដីបញ្ចប់នៃសាច់រឿងនោះយ៉ាងដូចម្ដេច?
- តើកូនអាចពិពណ៌នាអំពីការប្រែប្រួលនៅក្នុងតួអង្គ និងឆាកឈុតសាច់រឿងនោះបានទេ?
- តើកូនគិតថា អ្វីទៅជាអត្ថន័យនៅក្នុងរឿងនេះ?
- តើកូនអាចគិតថា រឿងនេះមានទំនាក់ទំនងនឹងព្រឹត្តិការណ៍ ឬបញ្ហាដទៃទៀតឬទេ?
- តើកូនយល់ស្របនឹងទស្សនៈផ្សេងៗរបស់អ្នកនិពន្ធទេ?
- តើកូនយល់យ៉ាងណាដែរ អំពីអត្ថន័យនៅក្នុងសាច់រឿងនោះ?
- តើអ្នកដទៃអាចយល់ឃើញខុសគ្នាយ៉ាងដូចម្ដេចទៅ?

## ការស្វែងរកអត្ថន័យនៃពាក្យពេចន៍លំបាកៗ



ការផ្ដល់ពេលវេលា និងយុទ្ធសាស្ត្រឲ្យកូនរបស់អ្នកក្នុងការអាន និងសរសេរពាក្យវែង ឬពាក្យដែលកូនរបស់អ្នកមិនធ្លាប់ស្គាល់គឺជារឿងសំខាន់។

មុនពេលប្រាប់ពាក្យដល់កូននៅពេលដែលកូនកំពុងអាន សូមសាកល្បងប្រើនូវតម្រុយដូចខាងក្រោម៖

- ពិនិត្យរកមើលតម្រុយផ្សេងៗសម្រាប់អត្ថន័យពាក្យនៅក្នុងឃ្លា។
- ពិនិត្យមើលពាក្យឲ្យបានល្អិតល្អន់។ តើពាក្យនេះដូចជាពាក្យមួយទៀតដែលកូនដឹងឬទេ?
- តើកូនអាចបំបែកពាក្យជាផ្នែកតូចៗបានទេ?
- តើពាក្យផ្សេងៗនៅពីមុខ និងពីក្រោយជួយប្រាប់តម្រុយទេ?

មុនពេលប្រកបពាក្យណាមួយសម្រាប់កូនរបស់អ្នកនៅពេលដែលកូនកំពុងសរសេរ សូមសួរនូវសំណួរដូចនេះ៖

- តើវាមើលទៅត្រឹមត្រូវទេ?

ជំរុញលើកទឹកចិត្តឲ្យកូនរបស់អ្នកអាន សរសេរ ឬ មើលអ្វីមួយដោយមានគោលបំណងមួយជាក់លាក់។ គំនិតខ្លះៗរួមមាន៖

- អានសៀវភៅ ឬការអត្ថាធិប្បាយវាយតម្លៃអំពីភាពយន្តតាមរយៈការចុចលើពាក្យ *Review* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សបឋមសិក្សា ហើយ បន្ទាប់មកពួកគេអាចបន្ថែមនូវគំនិតវាយតម្លៃរបស់ខ្លួនបាន។
- អាន ប្រមូល សាកល្បងជាមួយ និងសរសេរអំពីក្បួនធ្វើម្ហូបផ្សេងៗ ដើម្បីបង្កើតនូវសៀវភៅចម្អិនម្ហូប។
- ស្វែងរកនូវការពិតផ្សេងៗអំពីពិភពលោកតាមរយៈការចុចនៅលើពាក្យ *Find* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។
- ប្រើនូវកម្មវិធីឆ្លងឆ្លើយភ្លាមៗតាមអ៊ីនធើរណិត (instant messaging) ដើម្បីទាក់ទងជាមួយនឹងគ្រួសារ និងមិត្តភក្តិជាមួយគ្នា។
- រក្សាសៀវភៅកំណត់ត្រាមួយដែលកូនរបស់អ្នកអាចកត់ត្រានូវព្រឹត្តិការណ៍ និងអារម្មណ៍ផ្សេងៗ។



- បង្កើត និងសរសេរកាតសួរសុខទុក្ខ។
- សរសេរនូវបញ្ជីទិញទំនិញសម្រាប់គ្រឿងធ្វើម្ហូបដែលអ្នកនិងកូនរបស់អ្នកចង់ដាំស្ល។
- ថតរូបវីដេអូអំពីការវាយតម្លៃរបស់អ្នកដោយប្រើម៉ាស៊ីនថតសម្រាប់អ៊ីនធើរណិត (web camera) ឬ ប្រើម៉ាស៊ីនថតរូបធម្មតាដែលអាចថតវីដេអូបាន ឬក៏ប្រើទូរសព្ទចល័តដែលអាចថតវីដេអូបាន។ មើលវីដេអូផ្សេងៗទៀតដែលបានបង្កើតឡើងដោយកុមារឯទៀត ដោយចុចនៅត្រង់ពាក្យ *Watch* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សបឋមសិក្សា។
- ចូលរួមជាមួយនឹងវិបសាយថ៍ Wiki ដើម្បីអាន និងចូលរួមចែករំលែកគំនិតផ្សេងៗ។

## គម្រោងការងារជាលក្ខណៈគ្រួសារ

ឆ្លៀតយកឱកាសដើម្បីឲ្យក្រុមគ្រួសារទាំងមូលមាន ការចូលរួមនៅក្នុងការអាន និងការសរសេរ។ គម្រោងការងារជាលក្ខណៈគ្រួសារខ្លះអាចរួមមាន៖

- ការសរសេរអ៊ីមែលទៅមិត្តភក្តិ ឬក៏សមាជិកគ្រួសារ។
- ការប្រើបណ្តាញសង្គម (social networking sites) តាមអ៊ីនធើរណិតដើម្បីទាក់ទងជាមួយគ្រួសារ និងមិត្តភក្តិទាំងឡាយ។
- ការអានសៀវភៅរឿងភាគជាមួយគ្នា។



- ការអានសេចក្តីណែនាំផ្សេងៗសម្រាប់វត្ថុថ្មីណាមួយដើម្បីឲ្យដឹងអំពីរបៀបប្រើប្រាស់វត្ថុនោះ។
- ការថតព្រឹត្តិការណ៍នានារៀបចំឡើងជាលក្ខណៈគ្រួសារ ឬបទពិសោធន៍នៃការធ្វើដំណើរនៅក្នុងកូនសៀវភៅផ្ទាល់ខ្លួន ឬក៏សរសេរជាលក្ខណៈ blog នៅលើអ៊ីនធើរណិត។
- ការសរសេររឿងល្ខោន និងការសម្តែងរឿងទាំងនោះសម្រាប់គ្រួសារ និងមិត្តភក្តិ។
- ការលេងល្បែងដាក់តួអក្សរបំពេញពាក្យ (crosswords), ការតាមដានរកពាក្យល្បងប្រាជ្ញា (word puzzles), ការលេងល្បែងរំញោចខួរក្បាល (brain teasers), ការលេងល្បែងប្រើពាក្យ (word games)និងការឆ្លើយសំណួរជាមួយគ្នា។
- ការដើររកសៀវភៅនៅក្នុងបណ្ណាល័យ និងហាងលក់សៀវភៅទាំងឡាយជាមួយគ្នា។
- ការបង្កើតខ្សែភាពយន្តរួមគ្នាតាមរយៈការចុចនៅលើឃ្លា *Make a movie* ដែលមានភ្ជាប់នៅលើវិបសាយថ៍ *FUSE* សម្រាប់កូនសិស្សថ្នាក់បឋមសិក្សា។
- ការដើរតាមផែនទី ឬប័ណ្ណព័ត៌មានអំពីការដើរកម្សាន្ត រួមមានការមើលកាលវិភាគនៃការជិះយានយន្តសាធារណៈ និងផ្លាកសញ្ញាព័ត៌មានផ្សេងៗទៀតនៅឯតាមកន្លែងសាធារណៈ។

## រង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាន

រង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាន (Premier's Reading Challenge) គឺជាវិធីមួយដ៏ល្អសម្រាប់កូនសិស្សក្នុងរដ្ឋវិចតូរីយ៉ា ក្នុងការលើកកម្ពស់ការអានរបស់ពួកគេឲ្យកាន់តែប្រសើរឡើង។ រង្វាន់នេះជំរុញលើកទឹកចិត្តឲ្យកូនសិស្សអាន និងសម្រេចបាននូវការអានសៀវភៅឲ្យបាន១៥ ក្បាលឬច្រើនជាងនេះដើម្បីឈានដល់គោលដៅដែលបានកំណត់។ រង្វាន់នេះក៏មានរួមបញ្ចូលទាំងគំនិតផ្សេងៗសម្រាប់ចំណងជើងសៀវភៅផងដែរ។ សូមចូលទៅឆែកមើលរង្វាន់ពីអភិបាលរដ្ឋសម្រាប់ការខិតខំអាននៅវិបសាយថ៍៖
**http://www.education.vic.gov.au/prc/default.htm**